ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

3

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ

## ស្តីពី

# គ្រូបង្រៀន

បានទទួលការឯកភាព

ពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា

ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

# បុព្វកថា

វិស័យអប់រំជាកត្តាគន្លឹះមួយក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ដើម្បីធានានិរន្តរភាពក្នុងការអភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញ សំដៅជំរុញការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ គោលការណ៍ឱ្យសម្រេចតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លើយតបនឹងបរិបទខាងលើ និងបរិបទសកលភាវូបនីយកម្ម ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀនក្នុងគោលបំណងកំណត់យុទ្ធសាស្ត្រដើម្បីអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាពនិងភាពសក្តិសិទ្ធិ និងមានការទទួលស្គាល់ពីសង្គម។

គោលនយោបាយស្តីពីគ្រូបង្រៀន នឹងធានាឱ្យគ្រូបង្រៀនមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈតាមរយៈការបណ្តុះបណ្តាលមុនពេលបំពេញការងារនិងក្នុងពេលបំពេញការងារ។ គោលនយោបាយនេះបានបង្ហាញពីយុទ្ធសាស្ត្រសំខាន់ៗសម្រាប់យកទៅអនុវត្តសំដៅសម្រេចចក្ខុវិស័យ គោលបំណង និងគោលដៅដែលបានកំណត់។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះដៃគូអភិវឌ្ឍទាំងអស់ ដែលបានជួយគាំទ្រទាំងស្មារតីនិងសម្ភារៈ ដើម្បីធ្វើឱ្យសម្រេចគោលនយោបាយស្តីពីគ្រូបង្រៀនសម្រាប់ជាត្រីវិស័យក្នុងការអភិវឌ្ឍគ្រូបង្រៀន។

ក្រសួងសង្ឃឹមថា ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ផ្នែកឯកជន សហគមន៍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយស្តីពីគ្រូបង្រៀនឱ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ឹម_សិទ្ធី**

# មាតិកា

**១. សេចក្តីផ្តើម** ..... ១
**២. ចក្ខុវិស័យ** ..... ២
**៣. គោលបំណង** ..... ២
**៤. គោលដៅ** ..... ២
**៥. យុទ្ធសាស្ត្រ** ..... ២
៥.១ កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ ..... ២
៥.២ ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ..... ២
៥.៣ កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន ..... ២
៥.៤ អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ..... ៣
៥.៥ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា ..... ៣
៥.៦ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ ..... ៣
៥.៧ លើកទឹកចិត្តនិងរក្សាទុកគ្រូបង្រៀន ..... ៣
៥.៨ ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន ..... ៣
៥.៩ ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន ..... ៤
**៦. ផែនការសកម្មភាព** ..... ៤
៦.១ ការបង្កើតយន្តការ ..... ៤
៦.២ ការបង្កើតក្របខណ្ឌគតិយុត្ត ..... ៤
៦.៣ ការគាំទ្រហិរញ្ញវត្ថុ ..... ៥
៦.៤ ការបណ្តុះបណ្តាលធនធានមនុស្ស ..... ៥
៦.៥ ដំណើរការអនុវត្តគម្រោង ..... ៥
**៧. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ..... ៦
**៨. សេចក្តីសន្និដ្ឋាន** ..... ៧
**៩. សន្ទានុក្រម** ..... ៨

## ១. សេចក្តីផ្តើម

ការរីកចម្រើននៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងការស្វែងរកឧត្តមភាពនៅលើពិភពលោក បានជំរុញឱ្យប្រទេសនីមួយៗខិតខំធ្វើការប្រកួតប្រជែងផលិតផល និងសេវាកម្មរបស់ខ្លួន។ ធនធានមនុស្សជាកម្លាំងចលករក្នុងការសម្រេចបំណងប្រាថ្នានេះ។ គ្រូបង្រៀនត្រូវបានគេទទួលស្គាល់និងឱ្យតម្លៃខ្ពស់ថាមានតួនាទី និងភារកិច្ចដ៏សំខាន់ក្នុងការកសាងធនធានមនុស្ស និងផ្តល់វិភាគទានដល់ការអភិវឌ្ឍបុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និងសកលលោក។ ការទទួលស្គាល់នេះបានស្តែងចេញតាមរយៈការប្រារព្ធទិវាគ្រូបង្រៀនជារៀងរាល់ឆ្នាំ។ ចំណេះដឹង ជំនាញ សីលធម៌ និងលក្ខណសម្បត្តិដែលជាតម្រូវការចាំបាច់សម្រាប់គ្រូបង្រៀនមានការប្រែប្រួលទៅតាមតម្រូវការក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច វប្បធម៌ បច្ចេកវិទ្យានៃសង្គមពុទ្ធិ។

សហគមន៍អាស៊ានមានបំណងបង្កើនជីវភាព និងសុខុមាលភាពប្រជាជនតាមរយៈសកម្មភាពជាច្រើនដូចជា ការលើកកម្ពស់ការវិនិយោគវិស័យអប់រំ ការអភិវឌ្ឍធនធានមនុស្ស ការសិក្សាពេញមួយជីវិត ការអនុវត្តវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងគ្រប់សកម្មភាពអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ប្រការនេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្មពីគ្រូបង្រៀន។ ការសិក្សាក្នុងតំបន់ដោយប្រព័ន្ធវាយតម្លៃនិងវាស់វែងលទ្ធផលអប់រំ បានកំណត់គោលដៅក្នុងការអភិវឌ្ឍគោលនយោបាយគ្រូបង្រៀនដូចជា ការទាក់ទាញបេក្ខជនដែលមានសមត្ថភាពឱ្យចូលប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាព ការគាំទ្រនិងលើកទឹកចិត្ត និងការទទួលបានការដឹកនាំល្អ។

រាជរដ្ឋាភិបាលបានផ្តល់អាទិភាពក្នុងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សតាមរយៈការពង្រឹងគុណភាពវិស័យអប់រំដែលមានចែងក្នុងមុំទី១នៃយុទ្ធសាស្ត្រចតុកោណ។ ច្បាប់ស្តីពីការអប់រំមានគោលបំណងអភិវឌ្ឍធនធានមនុស្ស លើកកម្ពស់គុណភាពអប់រំ កំណត់សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលិកអប់រំដូចជា សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សិទ្ធិអភិវឌ្ឍខាងវិជ្ជាជីវៈ សិទ្ធិចូលរួមអភិវឌ្ឍស្តង់ដារអប់រំ សិទ្ធិទទួលសេវាអប់រំផ្សេងៗ ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងការបំពេញកាតព្វកិច្ចផ្សេងទៀត។ ប្រការនេះរួមចំណែកបំពេញសេចក្តីត្រូវការរបស់គ្រូបង្រៀននិងអ្នកសិក្សាឱ្យទទួលបាននូវចំណេះដឹង ជំនាញ សីលធម៌ និងមានលទ្ធភាពចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិប្រកបដោយគុណភាព។

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនរួមមាន ផែនការយុទ្ធសាស្ត្រវិស័យអប់រំ គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ និងគោលនយោបាយផ្សេងៗទៀត។ ដើម្បីឆ្លើយតបនឹងបរិបទនេះ ក្រសួងបានរៀបចំគោលនយោបាយស្តីពីគ្រូបង្រៀន ដើម្បីរួមចំណែកអភិវឌ្ឍធនធានមនុស្សឱ្យមានបុគ្គលិកលក្ខណៈពេញលេញ។

គោលនយោបាយស្តីពីគ្រូបង្រៀនមានវិសាលភាពលើការអប់រំសាធារណៈនិងឯកជនចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិនិងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។